ចំណេះដឹងជាមូលដ្ឋានភាគទី២

ស្តីពីការទទួលរងសារធាតុវិទ្យុសកម្ម

វិទ្យាស្ថានវិទ្យាសាស្ត្រនៃវិទ្យុព្យាបាលជាតិ ថ្ងៃទី 17 មីនា 2011

## ១-តើតំបន់ភាគកើតឬគេហៅថាខាន់តូជប៉ុន ដែលជាតំបន់ជុំវិញខេត្តហ្វ៊ូគូស៊ីម៉ាប្រមាណ២៥០គីឡូម៉ែត្រភាគខាងជើងទីក្រុងតូក្យូមានសុវត្ថិភាពពីការធ្លាយវិទ្យុសកម្មដែរឬទេ?

ប្រសិនបើយើងឮថាមានកំរិតវិទ្យុសកម្ម១០ដងឬ១០០ដងជាងកំរិតសុវត្ថភាពធម្មតាយើងគិតថាគំរិតនេះដូចជាគំរិតធ្ងន់ធ្ងរក៏ប៉ុន្តែជាការពិតវាឥតប៉ះពាល់ដល់សុខភាពទេ។

គេបានរាយការណ៍ថាកំរិតវិទ្យុសកម្មជាខ្ពស់បំផុតគឺ១មីក្រូស៊ីវែរត៍ក្នុង១ម៉ោងដែលត្រូវបានគេត្រួតពិនិត្យនៅ១ទីក្រុង៧ខេត្តនៅក្នុងរយៈវេលាម៉ោង៩ព្រឹកដល់ម៉ោង៥ល្ងាចថ្ងៃទី១៥ គឺ តូក្យូ គុឈីហ្គិ ហ្គីនម៉ា សៃតាម៉ា ឈីបា ខាន់ណាហ្គាវ៉ា យ៉ាម៉ាណាសី ស៊ីស៊្សឹអុកា។

កំរិតវិទ្យុសកម្មនេះជាកំរិតដែលឥតប៉ះពាល់ដល់សុខភាពទេពីព្រោះទោះបីជាយើងរស់នៅរយៈពេលមួយឆ្នាំក្នុងកំរិតវិទ្យុសកម្មនេះក៏បរិមាណការសរុបស្មើនឹងកំរិតវិទ្យុសកម្មនៅក្នុងការពិនិត្យដោយCÁTscànner មួយដង។

ជាពិតកំរិតវិទ្យុសកម្មនៅក្នុងរយៈពេលកំពូលស្រួចមិនបន្តរហូតទេ។

## ២-តើយើងអាចទទួលពិនិត្យមើលសុខភាព

## ក្រោយការទទួលរងសារធាតុវិទ្យុសកម្ម?

នៅថ្ងៃទី១៥និង១៦វិទ្យាស្ថានវិទ្យាសាស្រ្តនៃវិទ្យុព្យាបាលជាតិបានពិនិត្យមើលបុគ្គលិករបស់ក្រុមហ៊ុនTepcoនិងអ្នកធ្វើការក្បែរៗមជ្ឈមណ្ឌលនុយក្លេអ៊ែរហ្វូគូស៊ីម៉ាស្តីពីការទទួលរងសារធាតុវិទ្យុសកម្ម។

ក៏ប៉ុន្តែយើងបានដឹងថាគ្មាននរណាម្នាក់ត្រូវបានទទួលរងសារធាតុវិទ្យុសកម្មយ៉ាងខ្លាំងដែលត្រូវការការធ្វើឱយអស់ធាតុទេ។

ដូច្នេះហើយយើងគិតថាឥតចាំបាច់ការត្រួតពិនិត្យចំពោះអ្នកដែលអត់ទទួលប្រកាសស្តីពីតំរូវការស្ថិតនៅកន្លែងដែលបានបាំងពីវិទ្យុសកម្មឬតំរូវការជម្លៀសទេ។

ឯទៀតបច្ចុប្បន្ននេះនៅជម្រកយើងធ្វើត្រួតពិនិត្យការទទួលរងសារធាតុវិទ្យុសកម្មដោយសារតែសំរាប់គោលដៅទី១គឺដើម្បីឱ្យគេបញ្ជាក់ដឹងរំដោះពីទុក្ខព្រួយជាពិតថាវាតប៉ះពាល់ដល់សុខភាពទេ។

## ៣-តើយើងអាចធ្វើឱយអស់ធាតុវិទ្យុសកម្មនៅផ្ទះទេ?

យើងអាចធ្វើបាន។

យើងអាចធ្វើឱយអស់ធាតុដោយងូតទឹកនិងលាងសក់និងខ្លួនហើយបោកខោអាវ។

បានន័យថាយើងធ្វើឱយអស់ធាតុរាល់ថ្ងៃនៅក្នុងជីវិតរបស់យើង។

## ៤-នាងខ្ញុំមានផ្ទៃពោះ។

## តើនាងខ្ញុំអាចទទួលឥទ្ធិពលពីសារធាតុវិទ្យុសកម្មដែរឬទេ?

ស្ត្រីមានផ្ទៃពោះក៏វិធីការពារពីការទទួលរងសារធាតុវិទ្យុសកម្មដូចគ្នាដែរ។

គេថាកំរិតវិទ្យុសកម្មក្រោម១០០មីលីស៊ីវែរត៍ឥតប៉ះពាល់ដល់សុខភាពរបស់គភ៌(នាំឱ្យពិការភាពដូចជាការខូចទ្រង់ទ្រាយឬកង្វះខាតនៃគំនិតប្រាជ្ញា។ល។)ទេ។

ឯទៀតអំពីឥទ្ធិពលក្រៅពីខាងលើ(ដូចជាជំងឺមហារីកនៃរយៈពេលទារកនិងកុមារឬរយៈពេលមនុស្សធំពេញវ័យ)ចំពោះគភ៌មិនចាំបាច់ភ័យខ្លាចយ៉ាងខ្លាំងទេពីព្រោះយើងគិតថាអាចមានគ្រោះថ្នាក់ដែលបានស្មានពីកំរិតសារធាតុវិទ្យុសកម្មជាបរិមាណបន្តិចបន្តួចដែលប្រជាពលរដ្ឋអាចទទួលរងនៅក្នុងស្ថានការណ៍បច្ចុប្បន្ននេះតិចមែនទែនប្រៀបធៀបនឹងអាចមានគ្រោះថ្នាក់ដល់សុខភាពដោយសាររបៀបរស់នៅ។

ឯទៀតចំពោះស្ត្រីមានផ្ទៃពោះសូមកុំឱ្យលេបថ្នាំមានវត្ថុធាតុអ៊ីយ៉ូឌីនឬថ្នាំខ្ពុរមាត់និងថ្នាំសម្លាប់មេរោគដែលមានវត្ថុធាតុអ៊ីយ៉ូឌីនតាមគំនិតរបស់ខ្លួនឯង។